THE WORLD BANK
Working for a World Free of Poverty

GPOBA
The Global Partnership on Output-Based Aid

# សេចក្តីប្រកាសព័ត៌មាន

សេចក្តីប្រកាសព័តិមាន លេខ ២០០៩/១

**ទំនាក់ទំនង:**

*នៅវ៉ាស៊ីនតោន:*

**Cathy Russell**, ទូរស័ព្ទ (+1) 202 458 8124 crussell@worldbank.org

*នៅភ្នំពេញ:*

**សារឿន ប៊ូ** ទូរស័ព្ទ (855) 23 217 301
sbou@worldbank.org

## ការជួយឧបត្ថម្ភរបស់ GPOBA ដែលគ្រប់គ្រងដោយធនាគារពិភពលោក បានបង្កើនលទ្ធភាពទទួលសេវាទូរគមនាគមន៍សម្រាប់ប្រជាជនក្រីក្រ នៅតាមតំបន់ជនបទនៅកម្ពុជា

*ខេត្តគោលដៅ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និង ខេត្តពោធិ៍សាត់*

**វ៉ាស៊ីនតោន ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៩** – គ្រួសារក្រីក្រនៅក្នុងខេត្តចំនួនបួននៃខេត្តក្រីក្រនៅភាគខាងជើង និងភាគពាយព្យប្រទេសកម្ពុជា ពោលគឺ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និង ខេត្តពោធិ៍សាត់ នឹងទទួលអត្ថប្រយោជន៍ពីជំនួយឥតសំណងក្នុងទឹកប្រាក់ចំនួន ២,៦ លានដុល្លារអាមេរិក ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាទូរគមនាគមន៍ដែលត្រូវបានចុះហត្ថលេខាដោយធនាគារពិភពលោកដែលបំពេញមុខងារជាអ្នកគ្រប់គ្រងជូនភាពជាដៃគូពិភពលោកស្តីពីជំនួយផ្អែកលើទិន្នផល (Global Partnership on Output-Based Aid (GPOBA)) និងរាជរដ្ឋាភិបាលកម្ពុជា។

គ្រួសារក្រីក្រចំនួន ៥២.០០០ ឬ ប្រជាជនកម្ពុជាចំនួន ២៦០.០០០ នាក់ត្រូវបានគេរំពឹងថានឹងទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ តាមរយៈសេវាបណ្តាញទូរគមនាគមន៍កាន់តែប្រសើរឡើង និងការតម្លើងចំណុចប្រើសេវាសាធារណៈ ដែលនៅទីនោះ ប្រជាជននឹងអាចហៅឬទទួលទូរស័ព្ទបាន ក្នុងលក្ខណៈទៀងទាត់និងអាចទុកចិត្តបាន។

**ឯកឧត្តម ជិន ប៊ុនស៊ាន រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជា ដែលនឹងត្រួតពិនិត្យលើការអនុវត្តគម្រោងនេះ** បានមានប្រសាសន៍ថា: *"ការធានាឱ្យបាននូវលទ្ធភាពទទួលសេវាទូរគមនាគមន៍ជូនប្រជាជន ទាំងអស់នៅ*

*កម្ពុជា និងការផ្សារភ្ជាប់ ‘គម្លាត ឌីហ្សុីតាល់ គឺជាអាទិភាពមួយនៃអាទិភាពនានារបស់រាជរដ្ឋាភិបាល” “គឺដល់ពេលហើយដែលប្រជាជននៅតាមតំបន់ជនបទ គប្បីអាចទទួលអត្ថប្រយោជន៍ពីសេវាកម្ម ដូចគ្នាក្នុង គុណភាព និងតម្លៃដូចគ្នាដែលប្រជាជនតាមទីក្រុងបាននឹងកំពុងទទួលបានអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។”*

ទោះបីជាមានការកែលម្អនៅក្នុងសេវាទូរគមនាគមន៍ និងកំណើនចំនួននៃក្រុមហ៊ុនទូរគមនាគមន៍ក្តី ក៏លទ្ធភាពទទួលសេវានេះនៅតាមតំបន់ជនបទនៅតែគឺជាបញ្ហាប្រឈមមួយនៅកម្ពុជា ។ វិទ្យាស្ថានស្ថិតិជាតិប៉ាន់ស្មានថាមានគ្រួសារតែមួយប៉ុណ្ណោះក្នុងចំណោមគ្រួសារនៅជនបទចំនួនប្រាំមួយដែលមានទូរស័ព្ទមួយ ប្រៀបធៀបទៅនឹងជាង ៣០ ភាគរយនៃគ្រួសារនៅទីក្រុង ។ ឃុំនានានៅតាមតំបន់ជនបទនិងដាច់ស្រយាល ច្រើនតែមានលក្ខណៈមិនសូវទាក់ទាញខាងពាណិជ្ជកម្មចំពោះអ្នកផ្តល់សេវា ដោយសារចំណាយប្រតិបត្តិការខ្ពស់ និងចំណូលជាមធ្យមទាបក្នុងអ្នកប្រើម្នាក់ៗ ។

ជំនួយឥតសំណងរបស់ GPOBA នឹងផ្តល់ឧបត្ថម្ភធនជាទុនមួយដងសម្រាប់ការផ្តល់សេវាទូរស័ព្ទនៅតាមទីកន្លែងនានាបើពុំដូច្នោះទេនឹងត្រូវបានគេចាត់ទុកថាមិនមានលក្ខណៈអាចធ្វើពាណិជ្ជកម្មបានឡើយ ។ អ្នកផ្តល់សេវា នឹងត្រូវបានជ្រើសរើសក្នុងលក្ខណៈប្រកួតប្រជែង តាមរយៈនីតិវិធីដេញថ្លៃបើកទូលាយមួយ ។ ពួកគេនឹងមានសេរីភាពប្រើប្រាស់បច្ចេកវិទ្យាអ្វីក៏បាន ប៉ុន្តែត្រូវតែផ្តល់បណ្តាញនិងសេវាពេញលេញ ក្នុងគុណភាព និងតម្លៃមួយ ដូចជាបណ្តាញផ្សេងទៀតនៅកម្ពុជាអញ្ចឹងដែរ ។ អ្នកផ្តល់សេវាដែលដេញថ្លៃបាន នឹងគឺជាអ្នកដេញថ្លៃប្រកបដោយ គុណសម្បត្តិគ្រប់គ្រាន់ ដែលផ្តល់សេវាកំណត់នៅតាមតំបន់គោលដៅទាំងនេះ ក្នុងតម្លៃឧបត្ថម្ភធនទាបបំផុត និង ចុះកិច្ចសន្យាផ្អែកលើស្នាដៃឬ “ទិន្នផល”ជាមួយរាជរដ្ឋាភិបាល ។ អនុលោមតាមអភិក្រមផ្អែកលើទិន្នផលឧបត្ថម្ភ ធនភាគច្រើនរបស់ GPOBA នឹងត្រូវបានទូទាត់តែនៅក្រោយពេលដែលសេវាត្រូវបានផ្តល់ និងត្រូវបានផ្ទៀងផ្ទាត់ ដោយភ្នាក់ងារឯករាជ្យមួយ ។

**លោក ឈីម៉ាវ ហ្វាន ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា** មានប្រសាសន៍ថា *“ដោយជួយឱ្យគ្រួសារក្រីក្រនៅតាមភូមិជនបទដាច់ស្រយាលទទួលបានសេវាទូរស័ព្ទ គម្រោង GPOBA នេះ នឹងជួយកែលម្អលទ្ធភាពចូលដល់ទីផ្សារនិងលទ្ធភាពទទួលបានកាលានុវត្តភាពសេដ្ឋកិច្ចនៅតាមខេត្តក្រីក្របំផុត មួយចំនួននៃប្រទេសកម្ពុជា”*

គម្រោង GPOBA នឹងប្រើប្រាស់មូលនិធិពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (AusAID) និង ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (Sida) ។

###

**ព័ត៌មានអំពី GPOBA**

ភាពជាដៃគូពិភពលោកស្តីពីជំនួយផ្អែកលើទិន្នផល គឺជាភាពជាដៃគូមួយដែលគ្រប់គ្រងដោយធនាគារពិភពលោក ។ GPOBA ត្រូវបានបង្កើតឡើងក្នុង ឆ្នាំ ២០០៣ នៅពេលដំបូងគឺជាមូលនិធិក្នុងអាណត្តិព្យាបាលពហុស្ថាប័នផ្តល់ជំនួយ

មួយ ដើម្បីអភិវឌ្ឍអភិក្រម ជំនួយផ្អែកលើទិន្នផល (OBA) នៅក្នុងវិស័យផ្សេងៗជាច្រើន រួមមាន ហេដ្ឋារចនាសម្ព័ន្ធ សុខភាព និង អប់រំ។ ឧបត្ថម្ភធន OBA គឺសំដៅបង្កើតគ្រឿងលើកទឹកចិត្តឱ្យមានភាពស័ក្តិសិទ្ធិនិងជោគជ័យរយៈពេលវែងនៃគម្រោងអភិវឌ្ឍន៍នានា។

ស្ថាប័នផ្តល់ជំនួយបច្ចុប្បន្ននៃ GPOBA រួមមានក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលគឺជាសមាជិកមួយនៃក្រុមធនាគារពិភពលោក អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការបរទេសហូឡង់ (DGIS) ទីភ្នាក់ងារអូស្ត្រាលីសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (AusAID) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (Sida)។

ដើម្បីព័ត៌មានបន្ថែមស្តីពី GPOBA សូមមើលគេហទំព័រ: www.gpoba.org

ព័ត៌មានបន្ថែមស្តីពីការងាររបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័រ:
www.worldbank.org/cambodia